**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ...០៤...អន.ក្រ**

# អនុក្រឹត្យ

## ស្តីពីការបង្កើតគណៈកម្មការសំរបសំរួលការងារ ប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :**

- បង្កើតគណៈកម្មការសំរបសំរួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា-ថៃ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | សុខ | អាន | ប្រធាន |
| ២- | ឯកឧត្តម | ប្រាក់ | សុខុន | អនុប្រធាន |
| ៣- | ឯកឧត្តម | ព្រុំ | សុខា | សមាជិក |
| ៤- | ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | សមាជិក |
| ៥- | ឯកឧត្តម | ឡុង | វិសាលោ | សមាជិក |
| ៦- | ឯកឧត្តម | យូ | ស៊ិនឡុង | សមាជិក |
| ៧- | ឯកឧត្តម | មល់ | រឿប | សមាជិក |
| ៨- | ឯកឧត្តម | ក្រាញ់ | តូនី | សមាជិក |
| ៩- | លោក | ជា | វ៉ាន់ដេត | សមាជិក |

**ប្រការ ២ :**

- គណៈកម្មការនេះមានភារកិច្ចធ្វើប្រក្រតីនីយកម្មទំនាក់ទំនងកម្ពុជា-ថៃ ក្រោយឧបទ្ទវហេតុ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣ ។

**ប្រការ ៣ :**

- គណៈកម្មការសំរបសំរួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងការងារកម្ពុជា-ថៃ មានតួនាទីជាចំណុចកណ្តាលក្នុងការសំរបសំរួលកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងការធ្វើប្រក្រតីនីយកម្ម នៃទំនាក់ទំនងកម្ពុជា-ថៃ ។

**ប្រការ ៤ :**

- គណៈកម្មការសំរបសំរួលការងារប្រក្រតីនីយកម្ម នៃទំនាក់ទំនងការងារកម្ពុជា-ថៃ ត្រូវប្រមូលសរុបការងារទាំងឡាយដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសំរេចនេះ រាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៥ :**

- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីលើលិខិតផ្លូវការ ។

**ប្រការ ៦ :**

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

__កន្លែងទទួល :__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ-កាលប្បវត្តិ*